វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

ព្រឹត្តិបត្រព័ត៌មានរបស់

# វេទិកាស្តីអំពីបញ្ហាអភិវឌ្ឍន៍

ឆ្នាំទី ៤ លេខ ៣ | ប្រចាំខែ មករា-មិថុនា | ឆ្នាំ២០០៣

## វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ

**វេទិកា**នៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា គឺជាសមាគមអង្គការដែលមានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនិងក្នុងស្រុក។ គេបានបង្កើតវេទិកានេះឡើង ដើម្បីបំផុសការពិភាក្សា និងដើម្បីតាងនាមអោយទស្សនៈនានា របស់បណ្តាអង្គការមិនមែនរដ្ឋាភិបាលចំពោះបញ្ហាសំខាន់ៗ ដែលមានឥទ្ធិពលទៅលើការវិវឌ្ឍន៍នៃកម្ពុជា។ ការសំរបសំរួលយោបល់ចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនានា ទៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ គឺជាគោលដៅមួយរបស់កម្មវិធី ស្តីពីបញ្ហាអភិវឌ្ឍន៍។




**លើ**ឆាកអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយបានចូលរួមយ៉ាងសកម្ម ក្នុងការពិភាក្សាលើឯកសារទាំងឡាយស្តីពីយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ ការអភិវឌ្ឍន៍នៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនានា បានក្លាយទៅជាល័ក្ខខ័ណ្ឌដែលធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ បានទាមទារ នៅក្នុង ឆ្នាំ ១៩៩៩។ មុនដំបូង គេបានដាក់ល័ក្ខខ័ណ្ឌនេះដល់បណ្តាប្រទេសដែលអាចសក្តិសមនឹងបន្ធូរបន្ថយបំណុល ប៉ុន្តែក្រោយមក គេបានពង្រីកល័ក្ខខ័ណ្ឌនេះ ទៅដល់បណ្តាប្រទេសក្រីក្រទាំងឡាយ ដែលប្រាថ្នាចង់ទទួលបានឥណទានសម្បទានដូចជាកម្ពុជាជាដើម។ គំនិតនេះ បានចាប់ផ្តើមចេញពីការប្រឹងប្រែងនានា របស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីទទួលបានការបន្ធូរបន្ថយបំណុលសំរាប់បណ្តាប្រទេសក្រីក្រ និងពីការរិះគន់របស់សង្គមស៊ីវិលដែលថា ល័ក្ខខ័ណ្ឌជាគោលនយោបាយនានាដែលធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ បានកំណត់ចំពោះបណ្តាប្រទេសក្រីក្រ បានរំខានដល់ការសំរេចចិត្តថ្នាក់ជាតិ និងភាពជាម្ចាស់លើគោលនយោបាយអភិវឌ្ឍន៍ទាំងឡាយ។ ដោយហេតុនេះហើយ ទើបបានជាគេ បញ្ចេញគំនិតអោយមានឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនានា របស់ប្រទេសនិមួយៗផ្ទាល់ ដើម្បីអោយរដ្ឋាភិបាលទាំងឡាយ អាចមានឱកាសបង្កើតគោលនយោបាយអភិវឌ្ឍន៍ផ្ទាល់របស់ខ្លួន ដោយមានការប្រឹក្សាយោបល់ ជាមួយសង្គមស៊ីវិលនៅក្នុងសាមីប្រទេសទាំងនោះ។

**មក**ទល់នឹងពេលនេះ បទពិសោធន៍នានាបានបង្ហាញពីការខកចិត្តមួយចំនួនចំពោះដំណើរនៃការចូលរួមចំណែកនិងការបារម្ភមួយចំនួន ដែលថាមានការប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ នៅក្នុងល័ក្ខខ័ណ្ឌរបស់ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ លើបរិបទនានាស្តីពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម។ ម្យ៉ាងទៀត ក្នុងករណីភាគច្រើន ការមានឥទ្ធិពលទៅលើគ្នាទៅវិញទៅមក និងការពិភាក្សាគ្នារវាងរដ្ឋាភិបាលនិងសង្គមស៊ីវិល បានផ្តល់ផលក្នុងរូបភាព ថា គោលនយោបាយអភិវឌ្ឍន៍នានា និងការអនុវត្តន៍គោលនយោបាយ ទាំងនោះ ត្រូវបានគេលើកយកមកពិភាក្សាគ្នាដោយចំហជាងពីមុន។

### មាតិកា

១. វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និង NPRS ........................១
២. ស្តាប់ទស្សនៈប្រជាពលរដ្ឋមូលដ្ឋានស្តីអំពី NPRS....................................៤
៣. តើវិស័យវិស័យគន្លឹះ ៦ សំខាន់ៗពិតទទួលជោគជ័យឬទេ?..........................៥

គណៈកម្មាការនិពន្ធ: រ៉ាស្សែល ភីទ័រសិន ស្មោវ សិនិទ្ធ កែវ ចំរើន (NGO Forum)
អ្នកផ្តល់យោបល់: អ៊ឹង យក់ឃន (AMARA) អ៊ីវ បូរិន (WFP) ឈឹម វណ្ណដេត (SST) ឯក ប្រណី (PLG) ពុច សុធន (CCSP)
អ៊ីម៉ែល: ngoforum@ngoforum.org.kh chamroeun@ngoforum.org.kh

**ការ**ចូលរួមរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ក្នុងដំណើរការនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ បានចាប់ផ្តើមពីឆ្នាំ ២០០០ នៅពេលដែលរដ្ឋាភិបាលកំពុងរៀបចំពង្រាងនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ ធនាគារពិភពលោកពុំបានទាមទារ អោយមានការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងពង្រាងយុទ្ធសាស្ត្រនេះទេ ហើយពេលនោះ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលបានរៀបចំដំណើរការប្រឹក្សាយោបល់របស់ខ្លួនផ្ទាល់។ ក្រុមមួយរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលបានដឹកនាំធ្វើសម្ភាសន៍ និងការប្រជុំជាច្រើននៅតាមខេត្តចំនួនបួន ដើម្បីទទួលយកយោបល់ពីអង្គការមិនមែនរដ្ឋាភិបាល និងតំណាងនានានៃសង្គមស៊ីវិល។ បន្ទាប់មក មានសិក្ខាសាលាថ្នាក់ជាតិមួយ បានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ដែលក្នុងពេលនោះ អ្នកចូលរួមទាំងឡាយបាន ផ្តល់អាទិភាពទៅលើអនុសាសន៍នានា របស់អង្គការមិនមែនរដ្ឋាភិបាល សំរាប់ការកាត់បន្ថយភាពក្រីក្រ។ តែគួរអោយស្តាយណាស់ថា ដោយសារការផ្តល់អនុសាសន៍របស់អង្គការមិនមែនរដ្ឋាភិបាលប្រព្រឹត្តទៅយឺតពេក គេពុំបានបញ្ចូលវា ទៅក្នុងពង្រាងយុទ្ធសាស្ត្រនោះទេ។



**ក្នុង**ឆ្នាំ ២០០១ រាជរដ្ឋាភិបាលបានបង្កើតផែនការអភិវឌ្ឍន៏សង្គមសេដ្ឋកិច្ចប្រាំឆ្នាំរបស់ខ្លួន។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានប្រមូលអង្គការមិនមែនរដ្ឋាភិបាលពីវិស័យផ្សេងៗ ដើម្បីផ្តល់ជាអនុសាសន៍ ទៅលើពង្រាងនៃផែនការតាមវិស័យនានា។ គេបានចងក្រងអនុសាសន៍ របស់អង្គការមិនមែនរដ្ឋាភិបាលជាកសាររួមមួយ និងបញ្ជូនវាទៅក្រសួងផែនការ។ ឥទ្ធិពលចំបងនៃការរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ទៅក្នុងសេចក្តីរបស់ផែនការនេះ គឺគេបានបន្ថែមវគ្គខ្លីៗមួយចំនួន ស្តីពីវិមជ្ឈការ និងការគ្រប់គ្រងគ្រោះមហន្តរាយ ព្រោះក្នុងពង្រាងលើកមុន ឥតមានប្រការទាំងនេះទេ។ អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ក៏បានណែនាំខ្លះដែរទៅលើដំណើរការមួយចំនួន ដែលគេបានប្រកាន់យករួចហើយ ជាពិសេសប្រការទាក់ទងនឹងតំរូវការពេលវេលាច្រើនជាងមុន ការរៀបចំប្រសើរជាងមុន និងភាពចូលផ្លុងគ្នាល្អជាងមុន រវាងឯកសារផែនការថ្នាក់ជាតិពីរ ពោលគឺ ផែនការអភិវឌ្ឍន៏សង្គមសេដ្ឋកិច្ច និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។ យើងរីករាយណាស់ ដោយបានកត់សំគាល់ឃើញថា នៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ គេបានថែង អំពីការព្រមព្រៀងគ្នាមួយរវាងរដ្ឋាភិបាល និងក្រុមអ្នកផ្តល់ជំនួយ ស្តីពីការបញ្ចូលផែនការអភិវឌ្ឍន៏សង្គមសេដ្ឋកិច្ច និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ លើកក្រោយចូលគ្នាជាឯកសារតែមួយ។

**ក្នុង**ឆ្នាំ ២០០២ រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមធ្វើការ លើយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដោយបានជ្រើសរើសអ្នកឯកទេសផ្ទាល់របស់រដ្ឋាភិបាល និងបានរៀបចំសិក្ខាសាលាមួយចំនួន ដើម្បីផ្សព្វផ្សាយពត៌មានអំពីបញ្ហានេះ និងស្នើសុំយោបល់ចំពោះដំណើរការព្រាងកម្មវិធី។ ដោយហេតុនេះ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល បានបំផុសអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ អោយចូលរួមក្នុងការងារដែលសំរបសំរួលដោយរាជរដ្ឋាភិបាល ជាជាងបង្កើតវេទិកាដោយឡែក សំរាប់ពិភាក្សាអំពីយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។ ភាគច្រើននៃសិក្ខាសាលា បានប្រព្រឹត្តិទៅនៅតែទីក្រុងភ្នំពេញ ធ្វើអោយការចូលរួមពីខេត្តមានការលំបាក។ រាជរដ្ឋាភិបាលបានចាត់ចែងរៀបចំសិក្ខាសាលាថ្នាក់ខេត្តមួយចំនួនដែរ តែវាបានប្រព្រឹត្តិទៅនៅក្នុងដំណាក់ចុងក្រោយនៃការងារព្រាងឯកសារនេះ។

**នៅ**ដើមឆ្នាំ ២០០២ បណ្តាអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ បានសំរេចចិត្តថា កំរងអនុសាសន៏ប្រចាំឆ្នាំរបស់អង្គការមិនមែនរដ្ឋាភិបាល ជូនចំពោះអង្គប្រជុំនៃក្រុមពិគ្រោះយោបល់ (CG) នឹងផ្តោតទៅលើការកាត់បន្ថយភាពក្រីក្រ ហើយចាត់ទុកកំរងអនុសាសន៏នេះ ថាជាប្រភពដ៏សំខាន់នៃយោបល់ចូលរួម របស់អង្គការមិនមែនរដ្ឋាភិបាល ទៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។ កំរងអនុសាសន៏របស់អង្គការមិនមែនរដ្ឋាភិបាលនេះ គឺជាការប្រឹងប្រែងរួមគ្នា របស់សមាគមអង្គការមិនមែនរដ្ឋាភិបាលចំនួនបី រួមមាន គណៈកម្មការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) និង MEDiCam សមាគមនៃបណ្តាញអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការក្នុងវិស័យសុខាភិបាល ព្រមទាំងមានការរួមចំណែក ពីបណ្តាញទាំងឡាយនៃអង្គការមិនមែនរដ្ឋាភិបាល តាមវិស័យនានា។ ឯកសារចុងបញ្ចប់ រួមមានសេចក្តីថ្លែងការដ៏សំខាន់មួយ ហើយបន្ទាប់មកមានសេចក្តីថ្លែងការតាមវិស័យនានាចំនួន ២២ និងអត្ថបទចូលរួមមួយចំនួនទៀត។ នៅពេលដែលគេបានអញ្ជើញ ក្រុមអង្គការមិនមែនរដ្ឋាភិបាលតាមវិស័យទាំងឡាយ មកចូលរួមសិក្ខាសាលា ស្តីពីយុទ្ធសាស្ត្រជាតិ

កាត់បន្ថយភាពក្រីក្រ នាថ្ងៃទី ២៨-២៩ ឧសភា ពួកគេបានប្រើអត្ថបទតាមវិស័យនិមួយៗ របស់គេជាយោបល់ចូលរួមជាលាយលក្ខណ៍អក្សរ ដល់ក្រុមពិភាក្សាតូចៗទាំងឡាយ។ ប្រតិភូរបស់អង្គការមិនមែនរដ្ឋាភិបាល ក៏បានថ្លែងអំពីកំរងអនុសាសន៍នេះផងដែរ នៅក្នុងអង្គប្រជុំនៃក្រុមពិគ្រោះយោបល់ (CG) នាថ្ងៃទី ១៩-២១ មិថុនា ២០០២។ ក្រសួងផែនការបានអញ្ជើញបណ្តាអង្គការមិនមែនរដ្ឋាភិបាលអោយទៅថ្លែងការពេញសមត្ថភាព និងចូលរួមជាអ្នកពិភាក្សា នៅក្នុងសិក្ខាសាលានានាស្តីពីយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដែលប្រព្រឹត្តិទៅក្នុងខែមេសា សីហា និង វិច្ឆិកា នៅទីក្រុងភ្នំពេញ។ ក្រសួងក៏បាន អញ្ជើញអោយបណ្តាអង្គការមិនមែនរដ្ឋាភិបាល អោយបញ្ជូនប្រតិភូរបស់ខ្លួនទៅចូលរួមក្នុងអង្គប្រជុំនានា នៅឯអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសំរាប់អភិវឌ្ឍន៍សង្គមផងដែរ។




**សកម្ម**ភាពផ្សេងទៀត របស់បណ្តាអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងពេលព្រាងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ រួមមានវេទិកានានាស្តីពី " ការកាត់បន្ថយភាពក្រក្រដល់ស្ត្រីទាំងឡាយ" ដែលរៀបចំធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល *អង្គការចំរើនស្ត្រី* (Women for Prosperity) រួមជាមួយក្រុមនានា ដូចជា *អាម៉ារ៉ា* នៅប៉ៃលិន បាត់ដំបង ពោធិសាត់ នៅក្នុងខែ មិថុនា និង ក្រោយមក ធ្វើបទបង្ហាញជាវេទិកានៅភ្នំពេញ។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលក៏បានសំរបសំរួលផងដែរ នូវការពិភាក្សាមួយ រវាងសមាជិកនានានៃព្រឹទ្ធសភា និងសភាជាតិ ជាមួយតំណាងទាំងឡាយនៃប្រជាជនក្រីក្រ រួមមានតំណាងសហជីពកម្មករម្នាក់ អ្នករកស៊ីផ្លូវភេទម្នាក់ គ្រួសារមួយដែលរងគ្រោះដោយថ្នាំញៀន គ្រួសារមួយដែលរងគ្រោះដោយភាពរាំងស្ងួត និងតំណាងនានានៃសហគមន៍នេសាទ និងសហគមន៍ព្រៃឈើ។ ក្រៅពីនេះ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល បានជំរុញអោយបញ្ចូលលទ្ធផលទាំងឡាយដែលរកឃើញ ផ្តល់មូលនិធិដោយ ADB លើដំណើរការចូលរួមវាយតំលៃភាពក្រីក្រនៅតាមភូមិចំនួន ១៥៤ ក្នុងបណ្តាខេត្តទាំង ២៤ ទៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ។

**ក្នុង**ពេលព្រាងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ បានផ្តល់គំនិត និងបញ្ហាជាច្រើនទៅក្នុងការពិភាក្សា រួមមានបញ្ហាអន្តរវិស័យមួយចំនួនៈ

- **អង្គការ**មិនមែនរដ្ឋាភិបាលខ្លះបានបញ្ជាក់ថា គេចង់ដឹង ពីសម្មតិកម្មសំខាន់ៗ ជាមូលដ្ឋានរបស់វិធីទាំងឡាយពីមុន ដែលគេបានប្រើសំរាប់វាយតំលៃ លើការថយចុះនៃភាពក្រីក្រ ជាពិសេស សម្មតិកម្មមួយទាក់ទងនឹង ការទុកចិត្តជ្រុលទៅលើកំណើនសេដ្ឋកិច្ច និងទៅលើផលជា "ការសាយភាយភោគទ្រព្យបន្តិចម្តងៗ ពីអ្នកមានទៅអ្នកក្រ" ដើម្បីទាញប្រជាជន អោយចេញផុតពីភាពក្រីក្រ។ ពួកគេបានបញ្ជាក់ពីភាពចាំបាច់នៃការវិភាគមូលហេតុរបស់ភាពក្រីក្រ ដែលត្រូវប្រើជាជំនួយដល់ការជ្រើសរើស គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសេដ្ឋកិច្ច ដ៏ទូលំទូលាយមួយ និងដើម្បីពិចារណាលើផលវិបាកសំខាន់ៗ របស់គោលនយោបាយទាំងឡាយ ក្នុងបរិបទនានានៃភាពក្រីក្រ។ ទន្ទឹមនឹងការទទួលស្គាល់ផលប្រយោជន៍នៃសមាហរណកម្មកម្ពុជា ទៅក្នុងទីផ្សារនានា តាមតំបន់ និងអន្តរជាតិ គេក៏ចាប់អារម្មណ៍ផងដែរថា ប្រការសំខាន់ស្មើគ្នានឹងនេះ គឺគេចាំបាច់ ត្រូវតែធ្វើសមាហរណកម្មសេដ្ឋកិច្ចនៃក្រុមសេដ្ឋកិច្ចតូចតាចទន់ខ្សោយទាំងឡាយ នៅក្នុងប្រទេសអោយចូលគ្នា ជាមួយចរន្តសេដ្ឋកិច្ចជាតិ។ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ បានទទួលស្គាល់ផ្នែកខ្លះ នៃប្រការនេះ ហើយបានបញ្ជាក់ពីបំណងរៀបចំការវាយតំលៃលើភាពក្រីក្រ និងផលប៉ះពាល់សង្គម ដើម្បីសិក្សាឥទ្ធិពលនៃគោលនយោបាយសេដ្ឋកិច្ចនានា។
- **ការ**បារម្ភមួយ ដែលវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលធ្លាប់បានលើកឡើង គឺភាពផ្ទុយគ្នារវាងការលើកផែនការថ្នាក់ជាតិ និងការលើកផែនការវិមជ្ឈកម្ម។ យើងរីករាយនឹងឃើញ " ជំហានបន្ទាប់មួយ " នៅក្នុងវគ្គចុងក្រោយនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដែលនិយាយពី "សិក្ខាសាលាមួយសំរាប់ពិភាក្សា លើភាពចូលផ្គុំគ្នានៃផែនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចលើកទីពីរ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ជាមួយនឹងផែនការអភិវឌ្ឍន៍នានា ថ្នាក់ខេត្ត និង ថ្នាក់ឃុំ"។
- **ការ**បារម្ភទៃទៀត ដែលតែងតែលើកឡើងដោយបណ្តាអង្គការមិនមែនរដ្ឋាភិបាល ក្នុងវិស័យសុខាភិបាល និងអប់រំ គឺបញ្ហាទាំងឡាយទាក់ទងនឹង ការបើកប្រាក់ចំណាយ ការបើកប្រាក់ចំណាយអោយទៅ

តាមបណ្ដាខេត្ត មិនទៀតទាត់ និងការចំណាយមិនគ្រប់គ្រាន់តាមតំរូវការ នៅក្នុងវិស័យសង្គម ដែលគឺជាអាទិភាពសំខាន់បំផុត។ អង្គការមិនមែនរដ្ឋាភិបាលជាច្រើនយល់ថា ត្រូវតែមានអាំងឌីកាទ័រ (សូចនាករ) ជាក់លាក់ សំរាប់បើកប្រាក់ចំណាយ កំណែទំរង់នៃវិស័យសាធារណៈ កំណែទំរង់បៀវត្ស និងអភិបាលកិច្ចល្អ។ ច្បាប់ចុងក្រោយនៃយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ បានបញ្ជាក់ពីបញ្ហាទាំងនេះជាច្រើន ប៉ុន្តែ អាំងឌីកាទ័រ (សូចនាករ) និងយន្តការតាមដានពិនិត្យ ដែលបានយល់ព្រម នៅឯកិច្ចប្រជុំ CG លើមុន នៅតែត្រូវការ ដើម្បីដាក់បញ្ចូលនៅក្នុង NPRS ។

**យុទ្ធ**សាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ(NPRS) គឺមានការឆ្លុះបញ្ចាំងយ៉ាង ទូលំទូលាយ នៃផែនការតាមវិស័យដែលមានស្រាប់ ម្លោះហើយ វាលំបាកណាស់ ដើម្បីវិនិច្ឆ័យឥទ្ធិពលនៃមតិយោបល់ NGO ទៅក្នុងឯកសារចុងក្រោយ។ វិស័យមួយចំនួន ដូចជា វិស័យសុខាភិបាល និង វិស័យអប់រំ បានពាក់ព័ន្ធជាមួយ NGO នៅក្នុងការអភិវឌ្ឍន៏ តាមរយៈផែនការខ្សែបណ្ដោយរបស់ក្រសួង តាំងពីដើមទីនាពេលដែល វិស័យផ្សេងៗទៀត មានភាពពាក់ព័ន្ធតិចតួចពី NGO។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា បានផលិតចេញជាឯកសារមួយចំនួន ដែលប្រៀបធៀបមតិយោបល់ NGO ទៅនឹងមាតិកានៃពង្រាងបន្ទបន្ទាប់ របស់ឯកសារ NPRS ឧទាហរណ៏ " ការប្រៀបធៀបភ្លាមៗនៃសេចក្ដីថ្លែងការណ៏ NGO សំរាប់កិច្ចប្រជុំពិគ្រោះយោបល់ស្ដីពីកម្ពុជា និង ពង្រាងលើកទីពីរនៃ ឯកសារ NPRS "។ ឥលូវនេះ យើងកំពុងចាប់ផ្ដើមវិភាគ អំពី NPRS ចុងក្រោយ ដើម្បីរកមើលថា តើវាពិចារណាល្អល្អិតល្អន់បានប៉ុណ្ណា នូវការព្រួយបារម្ភ របស់ NGO។ ក៏ប៉ុន្តែ ទោះបីជាយើងមិនអាចយល់ស្របនឹងអ្វីៗទាំងអស់ នៅក្នុង NPRS ក៏យើងនៅតែច្បាស់ក្នុងចិត្តថា មានចំណុចជាច្រើន ដែលចំណុចទាំងនោះ NGOs និង អ្នកពាក់ព័ន្ធទាំងអស់នឹងយល់ស្របជាមួយដែរ។

**យុទ្ធ**សាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) បានអនុម័តនៅចុងឆ្នាំ ២០០២ ។ នៅក្នុងខែ មិនា ២០០៣ សម្ដេចនាយករដ្ឋមន្ត្រីបានធ្វើជាអធិបតី សម្ពោធអោយដាក់អោយប្រើប្រាស់ជាផ្លូវការ នូវឯកសារថ្នាក់ជាតិ NPRS នៅឯសាលសន្និសិទចតុមុខ។ នៅចុងខែមិនាដដែលនោះ ក្រសួងផែនការបានរៀបចំការសម្ពោធថ្នាក់ខេត្តនៃ NPRS នៅក្នុងខេត្តបី ដែលមានអត្រាក្រីក្រខ្ពស់បំផុតៈ ខេត្តបន្ទាយមានជ័យ សៀមរាប និង ព្រៃវែង។

**វា**ជាការល្អ ដើម្បីកត់សំគាល់ថា ការឆ្ពោះទៅមុខរបស់ NPRS គឺថា " ទោះបី NPRS ទីមួយ មិនសុក្រិត និងអនុសាស៏មួយចំនួនរបស់អ្នកពាក់ព័ន្ធមិនទាន់បានដាក់បញ្ចូល ក៏ប៉ុន្តែវានឹងត្រូវគេកែលំអនៅពេលអនាគត ពីព្រោះវាជាយុទ្ធសាស្ត្ររំកិល និងការប្រឹងប្រែងបន្តពីក្រុមអ្នកពាក់ព័ន្ធទាំងអស់ ដែលធានាជាការចាំបាច់ថា គោលបំណងទាំងនេះ គឺបានមកដល់គោលដៅ។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជា សំលឹងរក ការទទួលយកសកម្មភាពគាំទ្រជាបន្ថែម និងការចូលរួមនៅក្នុងការអនុវត្តន៏ ការតាមដាន និងការវាយតំលៃនៃ NPRS" ។

**វេទិកា**អង្គការមិនមែនរដ្ឋាភិបាល មានជំនឿថា កត្តាសំខាន់បំផុត នៅក្នុងការសំរេចរាល់សុឆន្ទៈ នៅក្នុងឯកសារ NPRS គឺត្រូវតែធានាថា សកម្មភាពកាត់បន្ថយភាពក្រក្រី ដែលមានលើកនៅក្នុងឯកសារ ពិតជាបានអនុវត្តយ៉ាងពិតប្រាកដ ។ ដូច្នេះ វាតំរូវអោយមាន ការប្ដេជ្ញាចិត្តពីរាជរដ្ឋាភិបាល ម្ចាស់ជំនួយគាំទ្រ និងសកម្មភាពពាក់ព័ន្ធ របស់ NGOs និង សង្គមស៊ីវិល។

**ដើ**ម្បីលើកទឹកចិត្តជាសកម្មភាពចូលរួម វេទិកាអង្គការមិនមែនរដ្ឋាភិបាល បានរៀបចំក្រុមអ្នកសំរបសំរួល ចំនួន ១៨ នាក់ មកពី NGOs និងមកពីភ្នាក់ជំនួយ ក៏រិតថ្នាក់ខេត្តនិងជាតិ ដឹកនាំការពិភាក្សា នាកំឡុងពេល សម្ពោធអោយប្រើប្រាស់ NPRS ខេត្តចំនួនបី។ មានប្រាំមួយវិស័យ នៅក្នុង NPRS ត្រូវបានលើកធ្វើជាអាទិភាពៈ វិស័យកសិកម្ម វិស័យអភិវឌ្ឍន៏ជនបទ វិស័យអប់រំ វិស័យសុខាភិបាល វិស័យយេនឌ័រ និងវិស័យអភិបាលកិច្ច។ ហើយនេះគឺជា បញ្ហាមួយចំនួន ដែលលើកឡើងដោយ អ្នកចូលរួម នាពេលមានការពិភាក្សាអំពីបញ្ហាអស់ទាំងនេះ:

**ស្ដាប់ទស្សនៈប្រជាពលរដ្ឋមូលដ្ឋានលើយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ**

- តើ NPRS គឺជា ប្រភេទនៃការធ្វើផែនការតាមបែបមជ្ឈការឬ?
- តើផែនការនេះ មានការជាប់ពាក់ព័ន្ធជាមួយការអនុវត្តន៏ ដែលមានស្រាប់នៃកម្មវិធីសីលាឬទេ?
- អ្វីទៅជាគោលដៅអភិវឌ្ឍន៏សហស្សវត្ស?
- តើ NPRS នឹងអនុវត្តទៅយ៉ាងដូចម្ដេច?
- តើ NPRS មានបានស្ថាបនាទំនាក់ទំនងជាមួយផែនការអភិវឌ្ឍន៏មូលដ្ឋានដែរឬទេ?
- តើ ការអនុវត្តន៏ និងការតាមដាន/វាយតំលៃរបស់ NPRS និងផែនការថ្នាក់មូលដ្ឋានត្រូវមានទំនាក់ទំនងនឹងគ្នាយ៉ាងដូចម្ដេច?
- តើ NPRS ផ្ដល់ចំលើយបានប៉ុន្មានចំពោះសេចក្ដីត្រូវការមូលដ្ឋាន?

## វិស័យកសិកម្ម

- តើវិស័យកសិកម្មអាចធានាសន្តិសុខស្បៀង ជូនប្រជាពលរដ្ឋមូលដ្ឋានបានដែរឬទេ នាពេលអនាគត?
- តើអាចធានាទប់ទល់ ការហូរចូលផលិតផលកសិកម្ម ពីខាងក្រៅបានដែរឬទេ?
- តើមានវិធានការបែបណា ដើម្បីការពារគ្រោះធម្មជាតិ និងការពារផលដំណាំ របស់ប្រជាពលរដ្ឋ?
- តើត្រូវការពារផលអាក្រក់ ដែលជះឥទ្ធិពលលើវិស័យកសិកម្ម ដោយសារ ការពង្រីកវិស័យនានា ដូចជា វិស័យទេសចរ និង ឧស្សាហកម្មជាដើម ។ល។ យ៉ាងដូចម្តេច?

## វិស័យអប់រំ

- តើ NPRS លើវិស័យអប់រំ ពិតជាឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងក្តីសង្ឃឹមរបស់ប្រជាពលរដ្ឋជនបទដែរឬទេ?
- តើប្រើមធ្យោបាយណា ដែលមន្ទីរអប់រំខេត្ត នឹងសំរេចបានតាមគោលបំណងដែលមាននៅក្នុង NPRS?
- តើមន្ទីរអប់រំខេត្តនឹងបញ្ច្រាប ផែនការ និងសកម្មភាព ដែលមានស្រាប់ទៅក្នុង NPRS យ៉ាងដូចម្តេច?
- តើរកមធ្យោបាយណា ដើម្បីធានាពិតប្រាកដថា ការអនុវត្តន៍នៃ NPRS លើវិស័យអប់រំ ពិតជាមានប្រសិទ្ធភាព?

## វិស័យអភិវឌ្ឍន៍ជនបទ

- គួរមានការអប់រំនិងណែនាំបន្ថែមដល់ក្រុមប្រឹក្សាឃុំ និងមន្ត្រីថ្នាក់ខេត្ត ស្តីអំពី NPRS
- គួរជ្រើសរើសយុទ្ធសាស្ត្រពាក់ព័ន្ធនៃ NPRS ដាក់បញ្ចូលទៅក្នុង ផែនការអភិវឌ្ឍន៏ខេត្ត/ឃុំ
- គួរលើកអោយការយល់ដឹងអំពី NPRS នៅក្នុងចំណោមប្រជាពលរដ្ឋជនបទទូទៅ
- គួរប្រើប្រព័ន្ធផ្សព្វផ្សាយផ្សាយអំពី NPRS ទៅដល់មូលដ្ឋានប្រជាពលរដ្ឋក្រីក្រ ដើម្បីបានចូលរួមអនុវត្ត
- គួរមានតម្លាភាព និងគណនេយ្យភាពនៃប្រព័ន្ធគ្រប់គ្រងថវិកានៅកម្មវិធីអភិវឌ្ឍន៏និមួយៗ
- គួរបង្កើតប្រព័ន្ធតាមដាន/វាយតំលៃប្រចាំឆ្នាំ ឃ្លាំមើល ដំណើរការអនុវត្តន៍ និងផ្តល់អនុសាសន៏កែប្រែ
- គួរមាន NGOs ចូលរួមនៅក្នុងដំណើរការអភិវឌ្ឍន៏ធនធានមនុស្ស និងអនុវត្ត NPRS តាមមូលដ្ឋាន

## វិស័យសុខាភិបាល

- ហេតុអ្វីបានជា ផែនការសុខភាពមូលដ្ឋាននាពេលបច្ចុប្បន្ន នៃក្រសួងសុខាភិបាល មិនបានឆ្លើយតបទៅនឹងតំរូវការអ្នកស្រុក?
- ហេតុអ្វីបានជា ក្រសួងសុខាភិបាលសាងសង់ មណ្ឌលសុខាភាពមិនឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌភូមិសាស្ត្រ?
- ហេតុអ្វីបានជាមន្ត្រីសុខាភិបាលមិនអាចផ្តល់សេវា ដែលមានប្រសិទ្ធិភាពជូនប្រជាពលរដ្ឋក្រីក្រ?
- ហេតុអ្វីបាន ជារឿយៗ មន្ត្រីសុខាភិបាលអវត្តមាន នៅមណ្ឌលសុខភាពរបស់ខ្លួន?
- ហេតុអ្វីបានជា ការផ្គត់ផ្គង់ឱសថ និងសំភារៈពេទ្យផ្សេងៗ មិនបានដល់ដៃអ្នកក្រីក្រ?
- តើត្រូវអនុវត្តយ៉ាងដូចម្តេច ដើម្បីធានា ការប្រើប្រាស់ទុនសមធម៌ ពិតជាមានតម្លាភាព សំរាប់ជនក្រីក្រ?

## ទិស័យយេនឌ័រ

- គួរមាន កម្មវិធីការយល់ដឹងអំពីយេនឌ័រ នៅឯថ្នាក់មូលដ្ឋាន ភូមិ/ឃុំ និងក្រុមប្រឹក្សាឃុំសង្កាត់
- គួរមានកម្មវិធីពង្រឹងសមត្ថភាពស្ត្រី លើផ្នែកការកសាងសមត្ថភាព ដើម្បីអោយស្ត្រីអាចចូលរួមក្នុងសកម្មភាពការងារនយោបាយ និងសង្គមបាន
- តើ NPRS ពង្រីកឱកាសរកការងារ សំរាប់ជនក្រីក្រ ជាស្ត្រីតាមទីជនបទនៅកម្ពុជាយ៉ាងដូចម្តេច?
- តើ NPRS បញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់វិស័យ ដើម្បីបង្កើនការចូលរួម និងការសំរេចចិត្តយ៉ាងដូចម្តេច?
- តើ NGOs ចូលរួមយ៉ាងដូចម្តេចនៅក្នុង NPRS ដើម្បីអាចអភិវឌ្ឍយេនឌ័រនៅក្នុងសហគមន៍បាន?
- តើមានយន្តការអ្វី ដើម្បីធានាថា NPRS ពិតជាផ្តល់ សមភាព និង សមធម៌ សំរាប់យុទ្ធសាស្ត្រអនុវត្តយេនឌ័រ?

## ទិស័យអភិបាលកិច្ច

- តើមានយន្តការអ្វី ដើម្បីអនុវត្តអោយមានប្រសិទ្ធិភាពនៅក្នុងអភិបាលកិច្ចល្អ?
- តើ NPRS មានបានបញ្ជាក់អំពីយុទ្ធសាស្ត្រអ្វី ដើម្បីលុបបំបាត់អំពើពុករលួយ?
- តើធ្វើយ៉ាងដូចម្តេច ដើម្បីអោយប្រជាពលរដ្ឋដឹង អំពីការចំណាយរបស់រដ្ឋាភិបាលមានតម្លាភាព និងការចំណាយ មានភាពរលូនទៅមុខ?
- តើគួររៀបចំប្រព័ន្ធយុត្តិធម៌និងតុលាការយ៉ាងដូចម្តេច ដើម្បីធានាថា ជនក្រីក្រជនបទអាចទទួលបាននូវស្តង់ដារយុត្តិធម៌សមរម្យមួយ?
- តើត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីអាចធានាការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព យូរអង្វែង?

## The NGO Forum on Cambodia And The National Poverty Reduction Strategy (NPRS)

The NGO Forum on Cambodia is a membership organization for international and local NGOs working in Cambodia. The NGO Forum exists to promote discussion and to represent the views of NGOs on important issues affecting Cambodia's development. Facilitating and coordinating NGO input to the NPRS is one of the tasks of the NGO Forum's Development Issues Project.

Internationally, NGOs have been actively involved with discussions on national Poverty Reduction Strategy Papers (PRSP). The development of Poverty Reduction Strategies became a condition imposed by the World Bank and International Monetary Fund (WB and IMF) in 1999. It was first imposed on countries eligible for debt relief but later expanded to other poor countries that desire concessional loans such as Cambodia. The idea originated from NGOs efforts to obtain debt relief for poor countries and civil society criticism that the policy conditions imposed on poor countries by the WB and IMF were hampering national decision-making on and ownership of development policies. Thus, the idea of country-owned Poverty Reduction Strategy Papers was introduced to allow governments a chance to develop their own policies in consultation with their country's civil society.

International experience has so far shown some frustrations with the participatory process and some concerns that little has changed in terms of WB and IMF conditions on aspects such as trade liberalization. On the other hand, in most cases, greater interaction and discussion between government and civil society has resulted, with development policies and their implementation being discussed much more openly than before.

The Forum's involvement in the NPRS process started in the year 2000 when the government was preparing its Interim Poverty Reduction Strategy. The World Bank did not require civil society participation for the interim strategy, so the NGO Forum organized its own consultation process. An NGO Forum Team conducted interviews and meetings in four provinces in order to obtain the input of NGOs and civil society representatives. This was followed by a national civil society workshop in Phnom Penh in which participants prioritized NGO recommendations for poverty reduction. Unfortunately, NGO input was given late and was not incorporated into the interim strategy.

In 2001, the Royal Government of Cambodia (RGC) developed its five-year Socio-Economic Development Plan (SEDP). The NGO Forum brought together different NGO sectoral groups to provide comment on the draft sectoral plans. The NGO comments were compiled into a single document and forwarded to the Ministry of Planning. The main impact of NGOs' contribution to content of the plan was that short sections on decentralization and on disaster management were added; these issues had not been included in the previous drafts. The NGOs also made suggestions on process which were accepted, especially regarding the need for more time, better participation, and better coherence between the two national planning documents namely the SEDP and NPRS. NGOs are pleased to

note agreement between government and donors, as mentioned in the NPRS, that the next SEDP and NPRS will be merged and presented in a single document.

In 2002, the Royal Government of Cambodia began work on the NPRS, recruited its own participation specialist, and organized a number of workshops to provide feedback and to request comments during the drafting process. The NGO Forum, therefore, encouraged NGOs to join the participation process facilitated by the government rather than create any separate forums for discussing the NPRS. The majority of workshops were held in Phnom Penh making provincial participation difficult. The government managed to organize a number of provincial workshops, however, during the final phase of the drafting.

In early 2002, the NGOs decided that their annual NGO Statement to the Consultative Group (CG) Meeting would focus on poverty reduction and that this statement would be the main source of NGO input to the NPRS. The NGO Statement was a collaborative effort between three NGO membership organizations, namely the Cooperation Committee for Cambodia (CCC), the NGO Forum on Cambodia, and the MEDiCAM association of NGOs working in health, together with contributions from many different NGO sectoral networks. The final document included a main statement followed by 22 sectoral and issues papers. When the NGO sectoral groups were invited to the 28-29 May PRSP workshops, they used their sectoral papers as the main written contribution to the small group discussions. The NGO Statement was also presented by NGO delegates at the Consultative Group meeting on 19-21 June 2002. The NGOs were invited to make plenary presentations and to be discussants at the NPRS workshops in May, August and November in Phnom Penh. They were also invited to send delegates to meetings of the General Secretariat of the Council for Social Development.

Other activities of NGOs during the NPRS drafting included the “Poverty Reduction for Women” forums organized by the NGO *Women for Prosperity* together with groups like *Amara*, in Pailin, Battambang, Pursat, and Phnom Penh in June and later presented in a forum in Phnom Penh. The NGO Forum also facilitated a discussion between members of Cambodia’s Senate and National Assembly and representatives of the poor, including representatives of a trade union, a sex worker, a family afflicted by drugs, a family afflicted by drought, and fishing community and forest community representatives. The NGO Forum also encouraged better integration of the findings of the ADB-funded Participatory Poverty Assessment, carried out in 154 villages across 24 provinces, into the NPRS.

During the drafting of the NPRS, NGOs brought many ideas and issues to the discussion, including a number of the cross-sectoral concerns:

- Some NGOs have expressed a need to question the basic assumptions that underpin previous approaches to poverty reduction, especially an over-reliance on economic growth and the “trickle down” effect, in order to lift people out of poverty. They expressed a need for a causal analysis of poverty, which is used to inform macro and economy-wide policy choices, and to consider the consequences of all policies in poverty terms. Whilst recognizing the benefits of integrating Cambodia into regional and international markets, they felt that equally important is the need to integrate economically marginalized groups within the country to the local economy. While the NPRS only partly recognizes this, it does express a willingness to commission poverty and social impact assessments to examine the impact of economic policies.

- A concern, which the NGO Forum has previously raised, is the contradiction between national level planning and decentralized planning. The NGO Forum is happy to see one of the “Next Steps” in the final chapter of NPRS is a “Workshop to discuss consistency of SEDP II and NPRS with commune and provincial development plans.”

- Other concerns, raised especially by NGOs in the health and education sectors, are the problems of disbursement of funds, unpredictable disbursement of funds to provinces, and under expenditure in the priority social sectors. Many NGOs felt that clear indicators are needed for disbursements of funds, public sector reform, salary reform and good governance. The final NPRS expresses many of these concerns, but indicators and monitoring mechanisms agreed at the previous CG meeting still need to be included.

The NPRS is largely a reflection of the existing sectoral plans so it is hard to judge the impact of the NGO input on the final NPRS document. Some sectors, such as health and education, have involved NGOs in the development of line ministry plans from the beginning, while other sectors had less NGO involvement. The NGO Forum produced a number of documents which compared NGO input to the content of subsequent drafts of the NPRS, including for example “A Rapid Comparison of the NGO Statement to the CG Meeting and Second Draft of the NPRS”. The NGO Forum is only now beginning to analyze the final NPRS to see how well it reflects NGO concerns. However, even if NGOs may not agree with everything in the NPRS, there are surely many points with which NGOs and other stakeholders will agree.

The RGC approved the NPRS in late in 2002. In March 2003, the Prime Minister presided over the National Launching of the NPRS at the Chaktomuk National Theater. Later that month, the Ministry of Planning organized Provincial Launchings of the NPRS in the three provinces with the highest incidence of poverty, Banteay Meanchey, Siem Reap and Prey Veng.

It is good to note that the Forward to the NPRS says that “Even though this first NPRS is not perfect, and some of the recommendations of the stakeholders could not be accommodated, however, it will be improved in the future since it is a rolling strategy and continued effort from all stakeholders is needed to ensure that its objectives are reached. Hence the RGC looks forward to receiving further active support and participation in the implementation, monitoring and evaluation of the NPRS.”

The NGO Forum believes that the most important factor in achieving all the good intentions in the NPRS document will be to ensure that the poverty reduction activities specified in the document are actually implemented. This will require

government commitment, donor support and the active involvement of NGOs and civil society.

In order to encourage active involvement, the NGO Forum organized a group of 18 facilitators from NGOs and development agencies to lead discussions during the NPRS Launching in three provinces. Six sectors in the NPRS were given as priorities: Agriculture, Rural Development, Health, Education and Governance.  Here are some of the questions raised by participants during these discussions:

### Listen to the Local People's Perspectives on the NPRS:

- **Is NPRS a centralized kind of planning?**
- **What is the implication for the existing implementation of the SEILA Program?**
- **What are the Millennium Development Goals?**
- **How will the NPRS be implemented?**
- **What is the linkage between the NPRS and the Local Development Plan?**
- **How the implementation, monitoring and evaluation of NPRS link to the local plan level?**
- **How much does the NPRS respond to local needs?**

### Agricultural Sector

- **How can the agricultural sector ensure food security for local people?**
- **How can the agricultural sector ensure against a flood of imported agricultural products from outside?**
- **What are the measures to protect farmer products from natural disaster?**
- **How can we deal with the negative impact on agricultural sector due to the enlargement of tourism and industry sectors?**

### Rural Development Sector

- **Should educate and provide more guidance to Commune Councils and Provincial Staff about the NPRS.**
- **Should select relevant strategies of NPRS to input into the Provincial/Commune Development Plans.**
- **Should be awareness raising of the NPRS among rural people.**
- **Should create media system of NPRS for the rural poor so that they can participate in implementation.**
- **Should have transparency and accountability of financial management in each development program.**
- **Should have Annual Monitoring/Evaluation to watch the implementation process and recommend changes.**
- **Should have NGOs to participate in the development process and NPRS implementation at each location.**

### Education Sector

- **How will the Education Sector of the NPRS respond to the basic needs and aspirations of rural people?**
- **How will the Provincial Education Department achieve the objectives of the existing NPRS?**
- **How can the Provincial Education Department mainstream existing plans and activities into the NPRS?**
- **What is the way to ensure that NPRS implementation in the field of education will be efficient?**

### Health Sector

- **Why does the current Health Coverage Plan of the Ministry of Health not respond to local requirements?**
- **Why does the Ministry of Health not construct Health Centers based on geographical conditions?**
- **Why is it that health workers cannot provide efficient services for poor people?**
- **Why are health workers often absent from the Health Center?**
- **Why is it that medical supplies and other equipment cannot drop into the hands of the poor?**
- **How can we ensure that equity funds are spent properly to benefit the rural poor?**

### Gender Sector

- **Should have Gender Awareness Program at village and Commune Council levels.**
- **Should provide capacity building to women so that they can participate in both political and social work activities.**
- **How can the NPRS provide job opportunities for poor people such as women in the rural areas of Cambodia?**
- **How can the NPRS mainstream women in all sectors so that they can increase their participation and involvement in decision-making?**
- **How can NGOs participate in the NPRS so that they can develop gender equity in the community?**
- **What is the mechanism to ensure that the NPRS will provide equality and equity of the gender implementation strategy?**

### Governance Sector

- **What is the mechanism to efficiently implement Good Governance?**
- **How will the NPRS ensure elimination of corruption?**
- **How can the NPRS ensure that people know that government expenditure is transparent and smoothly spent?**
- **How should the NPRS organize the justice and judicial system to ensure that the rural poor can obtain an appropriate standard of justice?**
- **How can the NPRS ensure that Natural Resources Management will be sustainable forever?**



The NPRS is required by the World Bank as a precondition for its future loans to Cambodia. Therefore, NGOs should deeply consider whether the poor really benefit.